# សុន្ទរកថា
## ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
## តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីបើក«សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦
## និងទិសដៅការងារឆ្នាំ២០១៧»

រាជធានីភ្នំពេញ រសៀលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលជាទីរាប់អាន!*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ក្នុងពិធីបើក **«សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧»** នាពេលនេះ ហើយខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតពេលដ៏មមាញឹកអញ្ជើញចូលរួមក្នុងសន្និបាតដ៏មានសារៈសំខាន់នេះ និងញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅដោយភាពអធិកអធម ក្នុងបរិយាកាសរីករាយ។

ជាមួយគ្នានេះដែរ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថានទាំងអស់ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ ចិត្ត បញ្ញា និងស្មារតី ក្នុងការបំពេញតួនាទី ភារកិច្ច និងបេសកកម្មរបស់ខ្លួន ជូនជាតិ មាតុភូមិ និងប្រជាជន ដើម្បីបុព្វហេតុកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។

ការជួបជុំគ្នាថ្ងៃនេះ មិនត្រឹមតែជាសក្ខីភាពបញ្ជាក់នូវការចូលរួមអបអរសាទរចំពោះសមិទ្ធផលនានាដែលក្រសួងបរិស្ថានសម្រេចបានក្នុងរយៈកាលកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការគាំទ្រ ជំរុញ និងលើកទឹកចិត្តឱ្យក្រសួងបរិស្ថានបន្តខិតខំបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានកាន់តែខ្លាំងក្លាថែមទៀត ដើម្បីឆ្លើយតបនឹងបំណងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការកសាងសង្គមកម្ពុជាទំនើបមួយ ដែលមានបរិស្ថានល្អស្អាត និងការរស់នៅដោយចីរភាព សម្រាប់ជនគ្រប់រូប និងគ្រប់ៗជំនាន់។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបស្រាប់ហើយថា ការងារបរិស្ថានជាកិច្ចការសកល មានលក្ខណៈពហុវិស័យ ដែលត្រូវបានពិភពលោកបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយក៏ជាកិច្ចការ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងពិភពលោក ក្នុងការរួមគ្នាថែរក្សា ការពារ និងស្វែងរកវិធានការដោះស្រាយបញ្ហាប្រឈម ដើម្បីធានាបាន

នូវគុណភាពបរិស្ថាន តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី ការរស់នៅដោយចីរភាព និងសុវត្ថិភាពនៃភពផែនដីទាំងមូល។

ដើម្បីឆ្លើយតបទៅនឹងកិច្ចការដ៏មានសារៈសំខាន់នេះ ជាពិសេសនៅក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ តាមរយៈការធ្វើកំណែទម្រង់ស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ក៏ដូចជាការរៀបចំឱ្យមាននូវគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗ ព្រមទាំងចាត់វិធានការ និងអនុវត្តសកម្មភាពជាក់ស្តែងជាច្រើន។ ជាក់ស្តែង រាជរដ្ឋាភិបាលបន្តអនុវត្តស្មារតីបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដោយប្រកាន់ជំហរមិនផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី ហើយព្រមជាមួយនោះ បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ ដែលក្នុងនោះ គម្រោងមួយចំនួនត្រូវបាននិរាករណ៍ ហើយគម្រោងមួយចំនួនទៀតត្រូវបានរាជរដ្ឋាភិបាលបន្តពិនិត្យ និងតាមដានការអនុវត្តយ៉ាងខ្ជាប់ខ្ជួន។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានធ្វើការកែសម្រួលតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងការអភិរក្ស និងការអភិវឌ្ឍ ដោយបានសម្រេចផ្ទេរតំបន់ព្រៃការពារ និងអភិរក្សទាំងអស់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យមកនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ហើយផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចចំនួន៧៣ ពីក្រសួងបរិស្ថានឱ្យទៅនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលក៏បានចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ តាមរយៈការបង្កើត «គណៈកម្មការជាតិ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ» ក៏ដូចជាដាក់ចេញនូវសារាចរណែនាំលេខ ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវិធានការចាំបាច់ក្នុងការពង្រឹងគ្រប់គ្រងធនធានធម្មជាតិ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានវេទិកាស្តីពី «ការការពារ និងការគ្រប់គ្រងធនធានធម្មជាតិ» កាលពីខែសីហា ឆ្នាំ២០១៦ កន្លងទៅនេះ ដើម្បីផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធទាំងអស់បានជួបពិភាក្សា និងប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រមុខរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំក្រសួង ស្ថាប័នរដ្ឋ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការ និងប្រសិទ្ធភាពការងារគ្រប់គ្រងធនធានធម្មជាតិ ដែលការសម្រេចនៅក្នុងអង្គវេទិកាស្មើនឹងការសម្រេចរបស់អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ដោយសម្រេចឱ្យមានវេទិកាថ្នាក់តំបន់ចំនួន ៣ដង ក្នុងមួយឆ្នាំ និងវេទិកាថ្នាក់ជាតិម្តងក្នុងមួយឆ្នាំ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!***

អម្បាញ់មិញ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលទទួលបន្ទុកការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ បានរាយការណ៍អំពីវឌ្ឍនភាពការងាររបស់ក្រសួងបរិស្ថាននាពេលកន្លងមក ដោយបានរំលេចឱ្យឃើញនូវស្ថានភាព សមិទ្ធផល និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សមិទ្ធផលសំខាន់ៗ ដែលឯកឧត្តមរដ្ឋមន្ត្រីបានរំលេចក្នុងរបាយការណ៍ គឺពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នូវកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ក្នុងការបំពេញតួនាទី និងភារកិច្ចស្នូលរបស់ខ្លួន ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល និយាយជារួម និងការធ្វើទំនើបកម្មស្ថាប័នរបស់ក្រសួងបរិស្ថាន និយាយដោយឡែក។ ជារួម សមិទ្ធផលទាំងនេះ គឺពិតជាមិនអាចកាត់ផ្តាច់ចេញពីការចូលរួមសហការពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពជុំវិញខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាសហគមន៍មូលដ្ឋាននោះឡើយ។

ការធ្វើទំនើបកម្មស្ថាប័នរួមទាំងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងបរិស្ថាន គឺពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុង ការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការពង្រឹងរបៀបរបបការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងការពង្រឹងការអនុវត្តច្បាប់ ក៏ដូចជាបានរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការអនុវត្តកម្មវិធីជាតិ «កំណែទម្រង់រដ្ឋបាលសាធារណៈ» «កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» និង «កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ» របស់រាជរដ្ឋាភិបាល។ ការធ្វើទំនើបកម្មស្ថាប័ននេះ គឺបានធ្វើឱ្យកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព កាន់តែមានប្រសិទ្ធភាព និងមានភាពប្រសើរឡើងជាលំដាប់។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានមោទនភាពចំពោះសមិទ្ធផលដែលក្រសួងបរិស្ថានសម្រេចបានកន្លងមក ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ថ្លែងនៅក្នុងពិធីសម្ពោធ «អគារមេរតកតេជោ» និងបើកសន្និបាតក្រសួងបរិស្ថាន កាលពីខែកុម្ភៈ ឆ្នាំ២០១៦ ហើយខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួងបរិស្ថានបន្តការខិតខំប្រឹងប្រែងបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!*

ស្របពេលដែលប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ កំណើនប្រជាជននៅតាមទីប្រជុំជន និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក៏មានការកើនឡើងយ៉ាងឆាប់រហ័ស ដែលបាននាំមកនូវបញ្ហាប្រឈមជាច្រើន និងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់គុណភាពបរិស្ថាន តុល្យភាពប្រព័ន្ធអេកូឡូស៊ី សោភ័ណភាពទីក្រុង និងសុខមាលភាពសង្គម។ បណ្តាទីប្រជុំជនក្រុងធំៗបាន និងកំពុងប្រឈមនឹងការកើនឡើងនូវបរិមាណសំណល់រឹង រាវ ការរំខានដោយសម្លេង បញ្ហាកកស្ទះចរាចរណ៍ កំណើនតម្រូវការថាមពល ក៏ដូចជា កង្វះលំហបៃតង ដែលតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំរកដំណោះស្រាយជាបន្ទាន់ និងបង្កើនការយកចិត្តទុកដាក់ក្នុងការបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនឹងនេះ ការប្រែប្រួលអាកាសធាតុក៏បានជះឥទ្ធិពលអវិជ្ជមានដល់គ្រប់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីផងដែរ ដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តសហការគ្នាឱ្យបានជិតស្និទ្ធ ក្នុងការស្វែងរកវិធានការឆ្លើយតបឱ្យបានសមស្រប និងទាន់ពេលវេលា។

ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល មេត្តាយកចិត្តទុកដាក់ចូលរួមផ្តល់យោបល់ និងពិភាក្សាលើវិធានការសមស្រប និងកំណត់ការងារជាអាទិភាព ដែលស្របនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ។ ខ្ញុំសង្ឃឹមថាសន្និបាតរយៈពេលបីថ្ងៃនេះ នឹងផ្តល់ឱកាសគ្រប់គ្រាន់ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធទាំងអស់ បានពិនិត្យ ពិភាក្សា និងវាយតម្លៃលើលទ្ធផលការងារប្រចាំឆ្នាំរបស់ខ្លួន ដើម្បីស្វែងរកជម្រើសដ៏ប្រសើរ ក្នុងការកំណត់ទិសដៅការងារនិងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧។

ដើម្បីជាមូលដ្ឋានពិចារណា សម្រាប់ការដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការចំពោះមុខ ខ្ញុំសូមផ្តល់នូវអនុសាសន៍គន្លឹះមួយចំនួនដូចខាងក្រោម៖

**១. ការធ្វើទំនើបកម្មស្ថាប័ន៖** ក្រសួងត្រូវបន្តពង្រឹងការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យសម្រេចបានជោគជ័យ ដោយត្រូវបន្តខិតខំកសាងធនធានមន្ត្រីរាជការ ទាំងបរិមាណ និងសមត្ថភាពឆ្លើយតបនឹងទំហំការងារចំពោះមុខរបស់ក្រសួង តាមរយៈការរៀបចំផែនការបណ្តុះបណ្តាល ការកសាងសមត្ថភាព ទាំងក្នុងជំនាញរដ្ឋបាល ហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំ។

ជាមួយគ្នានេះដែរ ក្នុងក្របខ័ណ្ឌការងារគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងត្រូវបន្តជំរុញការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមថវិកាកម្មវិធី ដើម្បីធានាឱ្យបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសង្គតិភាពថវិកាជាតិ ក៏ដូចជាបន្តផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញចូលតែមួយឱ្យកាន់តែមានតម្លាភាពនិងគណនេយ្យភាព ព្រមទាំងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុបែបថ្មី សំដៅធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ និងការពង្រឹងការចុះបញ្ជីសារពើភ័ណ្ឌចលនទ្រព្យ និងអចលនទ្រព្យរបស់រដ្ឋ។

ជាងនេះទៅទៀត ក្រសួងត្រូវបន្តពង្រឹងការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចលើចំណុចអវិជ្ជមាន និងចន្លោះខ្វះខាត ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់មន្ត្រី បណ្តាអង្គភាព និងមន្ទីរក្រោមឱវាទក្រសួង ដើម្បីប្រសិទ្ធភាពការងារ ឆ្លើយតបនឹងការធ្វើទំនើបកម្មស្ថាប័ន។

ក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រ ខ្ញុំសូមឱ្យក្រសួងបរិស្ថានបន្តស្មារតីសហការល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរ៉ែ និងថាមពល និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការពន្លឿនដំណើរការរៀបចំ «**ក្រមបរិស្ថាន**» និង «**យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ឆ្នាំ២០១៦-២០២៣**» ដែលជាលិខិតតូបករណ៍គតិយុត្ត និងជាឯកសារតម្រង់ទិសដ៏សំខាន់ សម្រាប់ធានាដល់ប្រសិទ្ធភាពការងារ ក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។

**២. កិច្ចគាំពារបរិស្ថាន៖** ក្រសួងត្រូវបន្តយកចិត្តទុកដាក់លើការងារគ្រប់គ្រងសំណល់រឹង រាវ និងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបន្តខិតខំអនុវត្ត «កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន» ឱ្យមានប្រសិទ្ធភាព ជាពិសេសត្រូវជំរុញការអនុវត្តគោលការណ៍ 3R (Reduce Reuse Recycle) ដើម្បីកាត់បន្ថយបរិមាណសំរាម និងសំណល់រឹង។ ចំពោះវិធានការទប់ស្កាត់ការបំពុលបរិស្ថានគ្រប់ប្រភេទ ក្រសួងត្រូវបន្តតាមដាន

ត្រួតពិនិត្យការគ្រប់គ្រងគុណភាពទឹក ដី ខ្យល់ និងសំឡេង ដើម្បីជាមូលដ្ឋានវាយតម្លៃពីស្ថានភាពបំពុល និងដាក់ចេញនូវវិធានការបង្ការទុកជាមុន សំដៅធានាបាននូវគុណភាពបរិស្ថាន សុវត្ថិភាពជីវៈចម្រុះ និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងការរស់នៅដោយចីរភាព។ ក្រសួងត្រូវបន្តជំរុញការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើរាល់គម្រោងវិនិយោគសាធារណៈ និងឯកជន ហើយត្រូវបង្កើនការតាមដានត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការបំពុលបរិស្ថានឱ្យបានម៉ឺងម៉ាត់ ដើម្បីឱ្យគ្រប់គម្រោងវិនិយោគមានដំណើរការ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។ ទន្ទឹមនឹងនេះ ក្រសួងត្រូវជំរុញការអនុវត្តអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត «មូលនិធិបរិស្ថាន និងសង្គម» ឱ្យមានប្រសិទ្ធភាព ដើម្បីស្តារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលរងការខូចខាតពីសកម្មភាពអនុវត្តគម្រោង ក៏ដូចជាដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍មូលដ្ឋាន។

**៣. ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការអភិរក្សជីវៈចម្រុះ៖** ក្រសួងបរិស្ថានត្រូវបន្តពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ និងបន្តរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានា ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ។ ក្រសួងត្រូវបន្តសិក្សាវាយតម្លៃប្រព័ន្ធអេកូឡូស៊ី ប្រភេទសត្វ និងរុក្ខជាតិនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិឡើងវិញ និងរៀបចំបង្កើតឱ្យមានរបៀងអភិរក្សជីវៈចម្រុះ និងដើម្បីកំណត់តំបន់ និងរៀបចំផែនការគ្រប់គ្រង ក៏ដូចជាសម្រាប់ការបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ សំដៅពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងធនធានធម្មជាតិ និងកាត់បន្ថយទំនាស់នៃការប្រើប្រាស់ដីធ្លី។ ជាមួយគ្នានេះដែរ ក្រសួងក៏ត្រូវបន្តរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិឱ្យបានជាក់លាក់ និងត្រូវបន្តពិនិត្យលទ្ធភាពរៀបចំបង្កើតតំបន់ការពារធម្មជាតិថ្មីៗ បន្ថែមទៀត ដោយផ្អែកលើសក្តានុពលផ្នែកធនធានធម្មជាតិ ជីវៈចម្រុះ វប្បធម៌ និងប្រវត្តិសាស្ត្រ។ ក្រសួងត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីឧទ្យានុរក្សតាមរយៈវគ្គបណ្តុះបណ្តាលនានា ក៏ដូចជារៀបចំផែនការប្រើប្រាស់កម្លាំងមន្ត្រីឧទ្យានុរក្សនៅតាមតំបន់ការពារធម្មជាតិនីមួយៗ ឱ្យបានសមស្រប ដើម្បីឆ្លើយតបទៅនឹងទំហំតំបន់ការពារធម្មជាតិ និងវិសាលភាពការងារ។

ជាងនេះទៅទៀត ក្រសួងត្រូវបន្តជំរុញការសិក្សា និងការអនុវត្តគម្រោងរេដបូក (REDD+) តាមរយៈការវាយតម្លៃកម្រិតជឿជាក់ផែនទីបម្រែបម្រួលគម្របព្រៃឈើ ការកសាងផែនទីគម្របព្រៃឈើ និងការរៀបចំផែនការសកម្មភាពអនុវត្តសារពើភ័ណ្ឌកាបូនព្រៃឈើ នៅតាមទីតាំងអនុវត្តគម្រោងរេដបូកសាកល្បង។ ទន្ទឹមនឹងនេះ ក្រសួងក៏ត្រូវសិក្សា និងរៀបចំការអនុវត្តគោលការណ៍ «ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី» សាកល្បងនៅតាមតំបន់នានាដែលមានសក្តានុពល។

**៤. សហគមន៍តំបន់ការពារធម្មជាតិ៖** ក្រសួងត្រូវបន្តយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ ព្រមទាំងរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីៗ បន្ថែមទៀត ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់សហគមន៍ ក៏ដូចជាជំរុញការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ អភិរក្សជីវៈចម្រុះ និងរក្សាតម្លៃវប្បធម៌ និងប្រពៃណី

របស់បងប្អូនជនជាតិដើមភាគតិច។ ក្នុងន័យនេះ ក្រសួងត្រូវបន្តធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីកំណត់សក្តានុពលតំបន់សហគមន៍នីមួយៗ សម្រាប់រៀបចំកម្មវិធី និងគម្រោងលើកស្ទួយជីវភាពសហគមន៍នានា ដូចជា ការអភិវឌ្ឍកសិកម្ម និងទេសចរណ៍ធម្មជាតិ។ ជាមួយគ្នានេះដែរ ក្រសួងក៏ត្រូវសិក្សាកំណត់សក្តានុពលសម្រាប់រៀបចំបង្កើតរបៀងទេសចរណ៍ធម្មជាតិជាលក្ខណៈប្រព័ន្ធ។

ទន្ទឹមនឹងនេះ ក្រសួងត្រូវបន្តពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរធម្មជាតិរបស់ក្រុមហ៊ុនទាំងអស់ នៅក្នុងតំបន់ការពារធម្មជាតិនានា ដើម្បីធានាថា គម្រោងទាំងនោះត្រូវបានអនុវត្តស្របតាមគោលការណ៍ និងនីតិវិធី ដែលបានកំណត់ ជាអាទិ៍ កិច្ចសន្យា និងផែនការមេ។

អនុវត្តតាមស្មារតីនៃវេទិកាជាតិស្តីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ» កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ថវិកាជាតិប្រមាណ ១ពាន់លានរៀល ក្នុងឆ្នាំ២០១៧ សម្រាប់អនុវត្តគម្រោងសាកល្បងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិមួយចំនួន តាមរយៈការបង្កើតមុខរបរថ្មីៗ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍ និងដើម្បីកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ និងការប្រមាញ់សត្វ ដូច្នេះ ក្រសួងបរិស្ថានត្រូវយកចិត្តទុកដាក់រៀបចំ និងជំរុញការអនុវត្តគម្រោងសាកល្បងទាំងនេះឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

ក្នុងក្របខ័ណ្ឌហិរញ្ញប្បទាននិរន្តរភាព ក្រសួងត្រូវបន្តយកចិត្តទុកដាក់ក្នុងការចែករំលែកផលប្រយោជន៍ ដែលបានមកពីការអនុវត្តកម្មវិធី និងគម្រោងនានា ជាពិសេស គម្រោងរេដបូក និងគម្រោង «ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី» ដើម្បីជួយគាំទ្រដល់ការលើកកម្ពស់ជីវភាពសហគមន៍ ក៏ដូចជាការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

ជាងនេះទៀត ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពិនិត្យលទ្ធភាពក្នុងការផ្ទេរ «សហគមន៍ព្រៃឈើ» ដែលនៅក្នុង និងនៅជាប់តំបន់ការពារធម្មជាតិ មកឱ្យក្រសួងបរិស្ថានដើម្បីរៀបចំជា «សហគមន៍តំបន់ការពារធម្មជាតិ»។

ក្រសួងត្រូវបន្តសិក្សា និងរៀបចំបង្កើតតំបន់បេតិកភណ្ឌធម្មជាតិថ្មីៗបន្ថែមទៀត និងកំណត់តំបន់ការពារធម្មជាតិជុំវិញប្រាសាទ និងបុរាណស្ថានក្នុងតំបន់ការពារធម្មជាតិនានា។

**៥. ការអប់រំផ្សព្វផ្សាយបរិស្ថាន៖** ក្រសួងបរិស្ថានត្រូវបន្តគិតគូរឱ្យបានស៊ីជម្រៅលើការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ដើម្បីកែប្រែទាំងផ្នត់គំនិត និងឥរិយាបថរបស់ប្រជាពលរដ្ឋឱ្យស្រឡាញ់បរិស្ថាន និងមានស្មារតីចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបរិស្ថានត្រូវបន្តពង្រឹងកិច្ចសហការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ជាពិសេសជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងសកម្មភាពសិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីបរិស្ថាន ឱ្យបានកាន់តែទូលំទូលាយតាមរយៈការអភិវឌ្ឍកម្មវិធីសិក្សាបរិស្ថានគ្រប់កម្រិត ការអនុវត្តកម្មវិធីសាលាមេត្រីភាពបរិស្ថាន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ការជំរុញការអនុវត្តកម្មវិធីអារាមមេត្រីបរិស្ថាន ការបំផុសចលនាភូមិដ្ឋានបៃតង និងចលនាផ្ទះមេត្រីបរិស្ថាន។

ក្រសួងបរិស្ថានត្រូវបន្តបញ្ជ្រាបចំណេះដឹងបរិស្ថានឱ្យដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន សំដៅប្រែក្លាយ «ចំណេះដឹងបរិស្ថានឱ្យទៅជាការប្រតិបត្តិបរិស្ថាន» និងត្រូវបន្តជំរុញចលនាប្រឡងប្រណាំងតាមគ្រប់រូបភាព នៅទូទាំងប្រទេស និងផ្តល់រង្វាន់ដល់អ្នកមានស្នាដៃឆ្នើម ក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន សំដៅរួមចំណែកលើកទឹកចិត្តដល់រូបវន្តបុគ្គល នីតិបុគ្គល ស្ថាប័នរដ្ឋ គ្រឹះស្ថានសាធារណៈ វិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។ ជាមួយគ្នានេះដែរ ខ្ញុំសូមឱ្យក្រសួងបរិស្ថានបន្តធ្វើមជ្ឈការទិន្នន័យបរិស្ថាន និងសេវាកម្មព័ត៌មានភូមិសាស្រ្ត ដើម្បីជាប្រភពទិន្នន័យរួម សម្រាប់ក្រសួងពង្រឹងប្រសិទ្ធភាពនៃការងារគ្រប់គ្រងកម្មវិធីបរិស្ថានជាតិ។

**៦. ការអភិវឌ្ឍដោយចីរភាព៖** ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបន្តខិតខំសម្របសម្រួល និងសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាព ដើម្បីលើកកម្ពស់ការងារអភិវឌ្ឍដោយចីរភាព នៅតាមវិស័យនានា ស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព សំដៅធានាឱ្យបាននូវតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ។

ក្នុងន័យនេះ ខ្ញុំសូមឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បន្តជំរុញ និងលើកកម្ពស់ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ដើម្បីជាមូលដ្ឋានតម្រង់ទិសដល់ការរៀបចំ ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ដែលបញ្ចេញកាបូនតិច និងការអភិវឌ្ឍដោយចីរភាព។ ជាពិសេស ក្រសួងត្រូវបន្តជំរុញការរៀបចំ និងអនុវត្ត «ផែនការអភិវឌ្ឍន៍ទីក្រុងដោយនិរន្តរភាព» ដោយត្រូវរៀបចំ និងអនុវត្តគម្រោងសាកល្បងជំហានទី១ តាមគោលការណ៍ «ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី» និង «កម្រៃលើការបំពុល» នៅ**ទីក្រុងកែប** ដើម្បីសិក្សាដកបទពិសោធ និងជំរុញការអនុវត្តបន្ត សំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការវិភាជមូលធនធម្មជាតិ និងការកាត់បន្ថយការបំពុលបរិស្ថាន។

ជាងនេះទៅទៀត ខ្ញុំសូមឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បន្តខិតខំសម្របសម្រួល និងសហការជាមួយគ្រប់ភាគី ក្នុងការអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា ពិធីសារ ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជំរុញការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាបៃតង ព្រមទាំងការអនុវត្តកម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងជីវសុវត្ថិភាព។

ទន្ទឹមនឹងនេះ ខ្ញុំសូមឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបន្តសម្របសម្រួល និងសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការវិនិយោគ និងអភិវឌ្ឍន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាការកៀរគរធនធានសម្រាប់អនុវត្តសកម្មភាព ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជា ដើម្បីលើកកម្ពស់ការអភិវឌ្ឍបៃតងដែលបញ្ចេញកាបូនតិច ស្របតាមផែនការយុទ្ធសាស្រ្តជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

និងរបាយការណ៍ស្តីពីការចូលរួមរបស់កម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្នុងនាមភាគីសមាជិកកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!***

ខ្ញុំមានជំនឿយ៉ាងមុតមាំថា តាមរយៈសន្និបាតរយៈពេលបីថ្ងៃនេះ យើងទាំងអស់គ្នានឹងទទួលបាននូវឱកាសយ៉ាងពេញលេញ ក្នុងការចូលរួមចែករំលែកចំណេះដឹង និងបទពិសោធ ក្នុងការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដែលជាកិច្ចការតម្រូវឱ្យយើងបន្តចូលរួម គ្រប់គ្រង និងដោះស្រាយបញ្ហាឱ្យបានកាន់តែប្រសើរថែមទៀត ហើយអង្គសន្និបាតនឹងកំណត់បាននូវបញ្ហាអាទិភាព ទិសដៅការងារ និងផែនការសកម្មភាព ឆ្លើយតបនឹងតម្រូវការចំពោះមុខរបស់សង្គមជាតិ។ ខ្ញុំសង្ឃឹមថា មន្ត្រីយើងទាំងអស់គ្នានឹងបន្តអនុវត្តឱ្យបានជោគជ័យនូវរាល់ភារកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ជូន ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែង និងបញ្ហាប្រឈមចំពោះមុខរបស់សង្គមកម្ពុជា នាពេលបច្ចុប្បន្ន និងទៅអនាគត។

មុននឹងបញ្ចប់ ខ្ញុំសូមឱ្យក្រសួងបរិស្ថាន ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធបន្តនូវវប្បធម៌សហការល្អដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តផ្តល់នូវកិច្ចសហការ និងការគាំទ្រដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីឱ្យស្ថាប័ននេះមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបញ្ជ្រាប «ការអភិវឌ្ឍដោយចីរភាព» ទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងទិសដៅការងាររបស់ក្រសួងស្ថាប័នរៀងខ្លួន ពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិទាំងអស់ សូមប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមជូនពរឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តិទៅប្រកបដោយភាពជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កា។

ខ្ញុំសូមប្រកាសបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧» ចាប់ពីពេលនេះតទៅ៕

**សូមអរគុណ**!